# សេចក្ដីបង្រៀនជា
# គន្លឹះដំណោល
# របស់លោកដេរេក ព្រីនស៍

DEREK PRINCE

## អំបិលសំរាប់មនុស្សលោក

វត្តមានរបស់យើងធ្វើឱ្យអ្វីៗទាំងអស់មានភាពខុសប្លែក "អ្នករាល់គ្នាជាអំបិល សំរាប់មនុស្សលោក" (ម៉ាថាយ៥: ១៣)។ សេចក្ដីដែលព្រះយេស៊ូ មានព្រះបន្ទូលនេះ គឺព្រះ អង្គមិនគ្រាន់តែមានព្រះបន្ទូលទៅកាន់ពួកសិស្សរបស់ ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែក៏ចំពោះយើងទាំងអស់គ្នាដែលបាន ទទួលស្គាល់នូវសិទ្ធិអំណាចនៃសេចក្ដីបង្រៀនរបស់ទ្រង់ដែរ។ ព្រះយេស៊ូប្រៀបធៀប មុខងាររបស់យើង ទៅនឹងអំបិលសំរាប់មនុស្សលោក។ ការបញ្ជាក់អត្ថន័យរបស់ ទ្រង់ កាន់តែច្បាស់ នៅពេលដែលយើងពិចារណាការប្រើ ប្រាស់ នៃមុខងារទាំងពីរយ៉ាង

**របស់អំបិលទាក់ទងទៅនឹង ម្ហូបអាហារ៖ អំបិលផ្ដល់នូវរសជាតិហើយអំបិលទប់ស្កាត់ នូវភាពស្អុយរលួយ។**

## អំបិលផ្ដល់នូវរសជាតិ

ក្នុងនាមយើងជាគ្រីស្ទាន មុខងាររបស់យើងជាអំបិល គឺត្រូវផ្ដល់រសជាតិដល់មនុស្សលោក។ ព្រះជាម្ចាស់ទ្រង់សព្វព្រះហឫទ័យ នឹងរស់ជាតិនេះ។ អាហារដែលមិនមានរសជាតិ ក្លាយជាមានរសជាតិ និងអាចទទួលយកបាន នៅពេលដែលគេផ្សំគ្រឿងជាមួយអំបិល។ លោកយ៉ូបបានសួរសំនួរ ដែលប្រកបដោយវោហារថា៖ *«តើគេអាចបរិភោគម្ហូបសាប ដោយមិនបង់អំបិលកើតឬ?»* **(យ៉ូប៦:៦)**។ វត្តមានរបស់អំបិល បានធ្វើអោយមានភាពខុសប្លែក នេះបណ្ដាលឱ្យយើងរីករាយនឹងអាហារបើមិនដូច្នេះទេ យើងនឹងមិនព្រមបរិភោគអាហារនោះឡើយ។

វត្តមានរបស់យើង ធ្វើឱ្យមនុស្សលោកគាប់ព្រះហឫទ័យនឹងព្រះជាម្ចាស់ ហើយលើកតម្កើងព្រះហឫទ័យមេត្តាករុណារបស់ទ្រង់ ទៅកាន់មនុស្សលោក។ ដោយសារយើងនៅទីនេះ ព្រះជាម្ចាស់នៅតែបន្តដោះស្រាយជាមួយមនុស្សលោក ដោយព្រះគុណ និងដោយព្រះហឫទ័យមេត្តាករុណា ជាជាងការប្រើសេចក្ដីក្រោធ និង

ការវិនិច្ឆ័យទោស។ វត្តមានរបស់យើង បានធ្វើឲ្យមានភាពខុសប្លែក។ គោលការណ៍នេះ គឺត្រូវបានបង្ហាញយ៉ាងច្បាស់ នៅក្នុងករណីរបស់លោកអប្រាហាំ ក្នុងការទូលអង្វរអោយក្រុងសូដុម ដែលមានចែង នៅក្នុង **លោកុប្បត្តិ ១៨:១៦-៣៣**។ ព្រះអម្ចាស់ មានព្រះបន្ទូល មកកាន់លោកអប្រាហាំថា៖ ទ្រង់នឹងយាងទៅក្រុងសូដុម ដើម្បីមើលថា តើអំពើទុច្ចរិត របស់អ្នកក្រុងបានមកដល់ចំណុចកំពូល ដែលព្រះជាម្ចាស់អាចនឹងវិនិច្ឆ័យទោសបាន ដោយពុំចាំបាច់ពន្យាពេលទុកយូរទៀត។ បន្ទាប់មក លោកអប្រាហាំ បានដើរជាមួយព្រះអម្ចាស់ នៅតាមផ្លូវជាមួយព្រះអង្គ ហើយបានវែកញែកជាមួយទ្រង់អំពីស្ថានភាពនេះ។

# គោលការណ៍នៃការវិនិច្ឆ័យទោស

លោកអប្រាហាំ បានបង្កើតឡើងនូវ គោលការណ៍មួយជាលើកដំបូង ដែលមានមូលដ្ឋាន ដូចខាងក្រោម៖ វាមិនមែនជា ព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ ដែលការវិនិច្ឆ័យទោសធ្លាក់ ទៅលើមនុស្សសុចរិត រួមជាមួយមនុស្សអាក្រក់ដែរនោះ។ *«តើព្រះអង្គ នឹងធ្វើ អោយមនុស្សសុចរិតបាត់បង់ជីវិត រួមជាមួយមនុស្សសុចរិតមែនឬ?» លោកអប្រាហាំ បានទូលសួរ (នៅខទី២៣)។ «ព្រះអង្គធ្វើដូច្នេះមិនកើតទេ សូមកុំប្រហារជីវិតមនុស្សសុចរិត រួមជាមួយមនុស្សទុច្ចរិតឡើយ! បើមិនដូច្នោះទេ*

*មនុស្សសុចរិត នឹងត្រូវបាត់បង់ជីវិត ជាមួយមនុស្ស ទុច្ចរិតមិនខាន។ ព្រះអង្គធ្វើដូច្នេះមិនកើតទេ! ចៅក្រមនៃផែនដីទាំងមូលតោងតែវិនិច្ឆ័យទោសដោយយុត្តិធម៌។ » (ខទី២៥)។*

ព្រះអម្ចាស់បានធ្វើឱ្យវាមានភាពច្បាស់លាស់ នៅក្នុងពេលសន្ទនាដោយទ្រង់បានទទួលយកនូវគោលការណ៍ ដែលលោកអប្រាហាំបានទូលថ្វាយនោះ។ វាមានសារៈសំខាន់ណាស់ ដែលអ្នកជឿទាំងអស់ ត្រូវមានការយល់ដឹងពីចំណុចនេះ! នៅពេលដែលយើង ត្រូវបានប្រោសអោយបានសុចរិត ដោយមានជំនឿលើព្រះគ្រីស្ទ និងកំពុងដឹកនាំជីវិត ដែលពិតជាបង្ហាញពីជំនឿរបស់យើងមែននោះ វាមិនមែនជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ ក្នុងការរាប់បញ្ចូលទាំងយើង ទៅក្នុងការវិនិច្ឆ័យទោស ដែលព្រះអង្គយកមកដាក់លើមនុស្សទុច្ចរិតនោះ។

# មានកត្តាកំណត់ពីរយ៉ាង

ជាអកុសល គ្រីស្ទានជាញឹកញាប់ មិនយល់ពីការនេះទេ។ ហេតុអ្វី? ពីព្រោះ ពួកគេបានបរាជ័យ ក្នុងការបែងចែករវាងស្ថានភាពទាំងពីរ ដែលមើលពីក្រៅទៅអាចលេចឡើងស្រដៀងនឹងគ្នា ប៉ុន្តែតាមការពិត គឺខុសគ្នាទាំងស្រុង បើគិតតាមលក្ខណៈធម្មជាតិ និងហេតុផលនោះ។ ម្យ៉ាង មានការបៀតបៀន សម្រាប់ជាប្រយោជន៍

ដល់ពួកអ្នកសុចរិត ម្យ៉ាងទៀត ជាការជំនុំជំរះរបស់ព្រះជាម្ចាស់ មកលើពួកមនុស្សទុច្ចរិត។

ភាពខុសប្លែកគ្នា រវាងស្ថានភាពទាំងពីរនេះ ត្រូវបាននាំយកមក ដោយសេចក្តីថ្លែងការណ៍ ផ្ទុយគ្នាដូចខាងក្រោម។ ការបៀតបៀនមកលើមនុស្សសុចរិតកើតចេញពីមនុស្សទុច្ចរិត ដូច្នេះការបៀតបៀនចំពោះមនុស្សសុចរិត និងការវិនិច្ឆ័យទោសចំពោះមនុស្សទុច្ចរិតគឺមានភាពផ្ទុយគ្នាទាំងស្រុង បើគិតតាមប្រភពដើមពីគោលបំណងលទ្ធផលនៃស្ថានភាពទាំងពីរនេះ។

ព្រះគម្ពីរបានបង្រៀនយ៉ាងច្បាស់ថា គ្រីស្ទានត្រូវតែរំពឹងទុកជាមុនថា ពួកគេនឹងទទួលបាន នូវការបៀតបៀន។ នៅក្នុងសេចក្តីបង្រៀននៅលើភ្នំ ព្រះយេស៊ូបានមានព្រះបន្ទូល ទៅកាន់ពួកសិស្សថា៖ « *១០ មានពរហើយ អស់អ្នកដែលត្រូវគេបៀតបៀន ដោយព្រោះសេចក្តីសុចរិត ដ្បិតនគរស្ថានសួគ៌ជារបស់ផងអ្នកទាំងនោះ ១១ អ្នករាល់គ្នាមានពរ ក្នុងកាលដែលគេជេរ បៀតបៀន ហើយនិយាយបង្ខូសគ្រប់ទាំងសេចក្តីអាក្រក់ ពីអ្នករាល់គ្នា ដោយព្រោះខ្ញុំ* » ***(ម៉ាថាយ៥១០:១១)*** ។ លោកប៉ូលក៏បាន សរសេរទៅកាន់ធីម៉ូថេ ដូចគ្នាដែរថា៖ « *អស់អ្នកដែល ចង់រស់នៅ ដោយគោរពប្រណិប័តន៍ព្រះជាម្ចាស់ ក្នុង ព្រះគ្រិស្តយេស៊ូ មុខជាត្រូវគេបៀតបៀនដូច្នេះឯង* » ***(២ធីម៉ូថេ៣:១២)***។ ដូច្នេះគ្រីស្ទានត្រូវតែត្រៀមខ្លួនជានិច្ច ដោយស៊ូទ្រាំនឹងការបៀតបៀន

សម្រាប់សេចក្តីជំនឿនិង ផ្លូវនៃជីវិតរបស់ពួកគេ ដោយរាប់ទុកថាជាឯកសិទ្ធិមួយ ដ៏ពិសេសចំពោះពួកគេ។

មានការដកស្រង់ដូចគ្នានេះដែរ គ្រីស្ទានមិនគួរត្រូវបានរួមបញ្ចូល ទៅក្នុងការជំនុំជំរះរបស់ព្រះជាម្ចាស់មកលើពួកមនុស្សទុច្ចរិតទេ។គោលការណ៍នេះត្រូវបានថ្លែងជាច្រើនដង នៅក្នុងបទគម្ពីរ។ ក្នុង**១កូរិនថូស ១១:៣២** លោកប៉ូល បានសរសេរទៅកាន់អ្នកជឿថា៖ « *៣២ តែកាលណាយើងរាល់គ្នាត្រូវ ជាប់ជំនុំជំរះ នោះព្រះអម្ចាស់ទ្រង់វាយផ្ចាលយើងវិញ ដើម្បីកុំឲ្យយើងជាប់ទោសជាមួយនឹងលោកីយ៍ឡើយ »។* នេះបង្ហាញថាវាមានភាពខុសគ្នា រវាង ដំណោះស្រាយរបស់ព្រះជាម្ចាស់ជាមួយនឹងអ្នកជឿនិង ដំណោះស្រាយជាមួយនឹងអ្នកមិនជឿ។ ក្នុងនាមជាអ្នកជឿ យើងក៏អាចរំពឹងទុកពីបទពិសោធន៍នៃការទទួល ទណ្ឌកម្មពីព្រះជាម្ចាស់ដែរ។ ប្រសិនបើ យើងចុះចូល នឹងការប្រៀនប្រដៅហើយកំណាត់ជីវិតរបស់យើងអោយ មានសណ្តាប់ធ្នាប់ នោះយើងនឹងមិនទទួលរង នូវការវិនិច្ឆ័យទោស ដែលនឹងត្រូវធ្លាក់ទៅលើអ្នកមិនជឿ ឬ លោកីយ៍ជាទូទៅនោះទេ។ បំណងព្រះហឫទ័យរបស់ ព្រះជាម្ចាស់ក្នុងការកែតម្រង់យើង ជាអ្នកជឿ នោះគឺ ដើម្បីការពារយើងពីការទទួលរង នូវការជំនុំជំរះរបស់ ទ្រង់ទៅលើអ្នកមិនជឿ។

និក្ខមនំជំពូកទី៧ដល់ជំពូកទី១២ បានកត់ត្រាទុកនូវរបៀបដែលព្រះជាម្ចាស់បាននាំនូវការវិនិច្ឆ័យទោសទាំងដប់ ដែលកើនឡើងកាន់តែធ្ងន់ធ្ងរទៅៗ មកលើជនជាតិ អេស៊ីបដោយសារតែពួកគេបានបដិសេធមិនស្ដាប់តាម ព្យាការីរបស់ទ្រង់ គឺលោកម៉ូសេ និងលោកអើរ៉ុន ប៉ុន្តែ គ្មានគ្រោះកាចណាមួយក្នុងចំណោមគ្រោះកាចទាំងដប់នេះ មានការប៉ះពាល់ដល់ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ គឺជនជាតិអ៊ីស្រាអែល ដែលបានរស់នៅពាសពេញកណ្ដាលស្រុកអេស៊ីបនោះឡើយ។ នៅក្នុង**និកម្ខនំ ១១:៧** បានចែងពីហេតុផលថា៖ *«៧ ប៉ុន្តែ នៅក្នុងពួកកូនចៅ អ៊ីស្រាអែល ចាប់តាំងពីមនុស្សដល់សត្វ នោះសូម្បីតែឆ្កែ១ក៏នឹងមិនកំរើកអណ្តាតទាស់នឹងគេឡើយ នេះដើម្បីឲ្យអ្នករាល់គ្នាបានដឹងថា ព្រះយេហូវ៉ាទ្រង់រាប់សាសន៍អេស៊ីព្ទ និងសាសន៍អ៊ីស្រាអែលផ្សេងអំពីគ្នា»។ ការវិនិច្ឆ័យទោស មិនបានធ្លាក់មកលើជន*ជាតិអ៊ីស្រាអែលទេ ដោយសារតែព្រះអម្ចាស់«បានធ្វើឱ្យមានភាពខុសគ្នាមួយ» រវាងប្រជារាស្ត្ររបស់ទ្រង់ និងប្រជាជនរបស់ស្រុកអេស៊ីប។ សូម្បីតែ សត្វឆ្កែរបស់ស្រុកអេស៊ីប ក៏បានទទួលស្គាល់ភាពខុសគ្នានេះ! ហើយភាពខុសគ្នានេះ នៅតែមានសុពលភាព រហូតដល់សព្វថ្ងៃនេះ។

# តើមានមនុស្សប៉ុន្មាននាក់ទើបគ្រប់?

លោកអប្រាហាំបន្តការសន្ទនារបស់លោកជាមួយនឹងព្រះអម្ចាស់ អំពីអ្នកក្រុងសូដុម ហើយលោកអប្រាហាំបានព្យាយាមអះអាងថា យ៉ាងហោចណាស់ ក៏មានមនុស្សសុចរិតខ្លះដែរ ដែលចាំបាច់ត្រូវការពារទីក្រុងទាំងមូលពីការជំនុំជំរះ។ លោកបានចាប់ផ្តើមជាមួយហាសិបនាក់។ បន្ទាប់មក ដោយមានការរួមបញ្ចូលគ្នា ដ៏គួរឱ្យកត់សម្គាល់មួយនៃការគោរពនិងការព្យាយាម លោកបានធ្វើតាមវិធីរបស់គាត់រហូតបានចុះដល់ដប់នាក់វិញ។ នៅទីបំផុត ព្រះអម្ចាស់បានធានាចំពោះលោកអប្រាហាំថា ប្រសិនបើ ទ្រង់បានរកឃើញមនុស្សសុចរិត តែដប់នាក់ក្នុងក្រុងសូដុម ទ្រង់នឹងទុកទីក្រុងទាំងមូលព្រោះតែដប់នាក់នោះ។

តើប្រជាជនក្នុងក្រុងសូដុម មានចំនួនប៉ុន្មាននាក់? វានឹងមានការលំបាក ក្នុងការប៉ាន់ស្មាន ពីចំនួន ដ៏ពិតប្រាកដមួយ។ ទោះបីជាយ៉ាងណាក៏ដោយតួលេខនេះ គឺអាចប្រើបាន សម្រាប់បណ្តាទីក្រុងមួយចំនួនផ្សេងទៀតរបស់ស្រុកប៉ាឡេស្ទីនពីបុរាណ ដែលផ្តល់នូវស្តង់ដានៃការប្រៀបធៀបមួយ។ តាមរយៈ ការយកទីក្រុងផ្សេងទៀត មកដាក់ក្នុងរឿងនេះ យើងអាចនិយាយបានថា ចំនួនប្រជាជននៅក្រុងសូដុម នាសម័យលោកអប្រាហាំ គឺប្រហែលជាមិនតិចជាងដប់ពាន់នាក់ទេ។

ព្រះជាម្ចាស់បានធានាចំពោះលោកអប្រាហាំថា បើមានមនុស្សសុចរិតដប់នាក់ វត្តមានរបស់ពួកគេអាចរក្សាការពារទីក្រុងបាន ដែលយ៉ាងហោចណាស់ មានមនុស្សមួយម៉ឺននាក់ដែរ។ នេះជាការផ្ដល់នូវសមាមាត្រមួយ ដោយមួយក្នុងមួយពាន់។ មានសមាមាត្រដូចគ្នា «មួយក្នុងចំណោមមួយពាន់» ដែលបានផ្ដល់ឱ្យ ក្នុង**យ៉ូប ៣៣:២៣** និងនៅ**សាស្ដា៧:២៨** ហើយបទគម្ពីរទាំងពីរខនេះ បានបង្ហាញថាមួយនាក់ គឺជាមនុស្សម្នាក់ដែលមានសេចក្ដីសុចរិតដ៏ឆ្នើម ខណៈពេលដែលអ្នកនៅសល់ទាំងអស់ ធ្លាក់ចុះក្រោមស្ដង់ដាររបស់ព្រះជាម្ចាស់។

វាគឺជាការងាយស្រួល ក្នុងការពង្រីកសមាមាត្រនេះជារៀងរហូត។ វត្តមានរបស់មនុស្សសុចរិតដប់នាក់អាចរក្សាជីវិតសហាគមន៍មួយ ដែលមានមនុស្សមួយម៉ឺននាក់បាន។ វត្តមានរបស់មនុស្សសុចរិត មួយរយនាក់ អាចរក្សាជីវិតសហាគមន៍មួយ ដែលមានមនុស្សមួយសែននាក់បាន។ វត្តមានរបស់មនុស្សសុចរិត មួយពាន់នាក់អាចរក្សាជីវិតសហាគមន៍មួយ ដែលមានមនុស្សមួយលាននាក់បាន។ តើត្រូវមានមនុស្សសុចរិត ប៉ុន្មាននាក់ដើម្បីការពារប្រទេសជាតិមួយ ដែលធំដូចជាសហរដ្ឋអាមេរិក ដែលមានប្រជាជនរបស់ខ្លួន ប្រមាណជាងបីរយលាននាក់? ប្រហែលជាបីសែននាក់។

តួលេខទាំងនេះ គ្រាន់តែជាការសំអាងប៉ុណ្ណោះ។ តើបទគម្ពីរផ្ដល់ឱ្យយើងនូវមូលដ្ឋាន ឲ្យជឿថាអញ្ចឹងឬ?

ឧទាហរណ៍ បើពិតជាមានមនុស្សសុចរិតជាងមួយសែនប្រាំម៉ឺននាក់រស់នៅវាយប៉ាយ ដូចជាគ្រាប់អំបិលនៅទូទាំងសហរដ្ឋអាមេរិក តើនោះនឹងគ្រប់គ្រាន់ សម្រាប់ការពារប្រជាជាតិទាំងមូល ពីការជំនុំជំរះរបស់ព្រះជាម្ចាស់ និងធានាឱ្យបាន នូវការទទួលបានព្រះគុណ និងព្រះហឫទ័យមេត្តាករុណារបស់ទ្រង់បន្តទៀតឬទេ? វាគឺជាភាពល្ងីល្ងើដែលអះអាងថា ការប៉ាន់ស្មានបែបនេះ គឺជាការត្រឹមត្រូវ។ ទោះបីយ៉ាងណាក៏ដោយព្រះគម្ពីរនេះពិតជាបង្កើតគោលការណ៍ទូទៅ ដែលថាវត្តមានរបស់អ្នកជឿសុចរិត គឺជាកត្តាសម្រេចព្រះទ័យ នៅក្នុងដំណោះស្រាយរបស់ព្រះជាម្ចាស់ ជាមួយនឹងសហគមន៍មួយ។

ការនេះដឹកនាំយើង ឲ្យឆ្ពោះទៅកាន់ឥទ្ធិពលទីពីរ នៃវត្តមានរបស់គ្រីស្ទាន ដែលជា «អំបិលសំរាប់មនុស្សលោក»។

# អំបិលទប់ស្កាត់នូវភាពស្អុយរលួយ

នៅសម័យមុន មុនពេលដែលគេប្រើទូរទឹកកក ដែលមានជាតិគីមី នាវិកដែលបានយក សាច់ធ្វើដំណើរដ៏វែងឆ្ងាយ គេបានប្រើអំបិល ដើម្បីទប់ស្កាត់នូវភាពស្អុយរលួយ។ ដំណើរការនៃភាពស្អុយរលួយនេះ បានមានរួចទៅហើយ មុនពេលដែលសាច់នេះត្រូវបានគេប្រឡាក់អំបិលទៅទៀត។ ការប្រឡាក់អំបិលមិនបានលុបបំបាត់នូវភាពស្អុយរលួយនោះទេ ប៉ុន្តែវាបានចាប់ផ្តើម ពន្យា

ពេលនៃភាពស្អុយរលួយ សម្រាប់រយៈពេល នៃការធ្វើដំណើរដ៏វែងឆ្ងាយ ដូច្នេះនាវិក អាចបន្តបរិភោគសាច់ជាយូរថ្ងៃបាន ហើយបើយូរពេក ក៏មិនអាចបរិភោគបានទៀតដែរ។

វត្តមានរបស់យើងនៅលើផែនដី ក្នុងនាមជាសិស្សរបស់ព្រះគ្រិស្ត មានមុខងារដូចជាអំបិល ប្រឡាក់នឹងសាច់ដែរ។ដំណើរការនៃភាពស្អុយរលួយរបស់អំពើបាបគឺបានមានដំណើរការរួចទៅហើយ។ ការនេះត្រូវបានបង្ហាញយ៉ាងច្បាស់ នៅក្នុងគ្រប់ផ្នែកនៃជីវិតមនុស្ស-សីលធម៌ សាសនា សង្គម នយោបាយ។ យើងមិនអាចលុបបំបាត់នូវភាពស្អុយរលួយ ដែលមានវត្តមានរួចទៅហើយនោះទេ ប៉ុន្តែយើងអាចចាប់ផ្តើមធ្វើការពន្យាពេលបានយូរគ្រប់គ្រាន់ ដើម្បីឲ្យបំណងព្រះហឫទ័យ នៃព្រះគុណ និងសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់ត្រូវបានធ្វើការយ៉ាងពេញលេញ។ បន្ទាប់មក នៅពេលដែលឥទ្ធិពលរបស់យើង មិនអាចនៅយូរទៀតបាន ភាពស្អុយរលួយនឹងមកដល់កម្រិតខ្ពស់បំផុតរបស់ខ្លួន ហើយលទ្ធផលនេះនឹងនាំឲ្យមានការខូចទាំងស្រុង។

ឧទាហរណ៍នេះបង្ហាញពីអំណាចរបស់អំបិល ក្នុងការទប់ស្កាត់ភាពស្អុយរលួយ ដែលបានពន្យល់ នៅក្នុងសេចក្តីបង្រៀនរបស់លោកប៉ូល ក្នុង**២ថែស្សាឡូនីច ២:៣-១២**។ លោកប៉ូលបាន ព្រមានថាអំពើអាក្រក់របស់មនុស្ស នឹងឈានដល់កម្រិតខ្ពស់បំផុតរបស់ខ្លួន តាម

រយៈមនុស្សម្នាក់ គឺជាអ្នកគ្រប់គ្រងពិភពលោក ដោយមានអំណាចហួសពីនិស្ស័យធម្មជាតិ ដែលត្រូវបានផ្តល់អំណាចនិងដឹកនាំដោយមារសាតាំងផ្ទាល់។ លោកប៉ូលបានហៅអ្នកគ្រប់គ្រងនេះថា៖ *«មនុស្សជាតួបាប (ទទឹងច្បាប់)»* ហើយជា *«មេប្រឆាំងសាសនា ដែលត្រូវវិនាស» (៦៣)*។ ក្នុង**១យ៉ូហាន២:១៨** វាត្រូវបានគេហៅថា៖«មេប្រឆាំងព្រះគ្រិស្ត» និងនៅក្នុង**វិវរណៈ ១៣:៤** វាត្រូវបានគេហៅថា«សត្វ តិរច្ឆាន»។ មេគ្រប់គ្រងនេះ ពិតជានឹងអះអាងថាខ្លួន គឺជាព្រះជាម្ចាស់ និងទាមទារ ឲ្យមានការថ្វាយបង្គំវាជាសកល។ ការវិនាសយ៉ាងទាន់ហន់របស់ មេគ្រប់គ្រងនេះ ពិតជាជៀសមិនផុតឡើយ។ លោកប៉ូល បាននិយាយដោយភាពជឿជាក់ថា៖ *«នោះទើបអាទទឹង ច្បាប់នោះនឹងលេចមក»* ដែលព្រះអម្ចាស់បានបង្ហាញ ឱ្យដឹង» **(២ថែស្សាឡូនីច២:៨)**។ លោកប៉ូលក៏បាន ប្រកាសផងដែរ នៅក្នុងខដដែលថាព្រះគ្រិស្តពិតប្រាកដ នឹងធ្វើការវិនិច្ឆ័យទោសជាចុងក្រោយទៅលើព្រះគ្រិស្ត ក្លែងក្លាយនេះ ដោយព្រះអង្គផ្ទាល់ *«ហើយព្រះអម្ចាស់ យេស៊ូនឹងបំផ្លាញវាដោយខ្យល់ដែលចេញពីព្រះឱស្ឋ របស់ព្រះអង្គ រួចហើយ នៅពេលព្រះអង្គយាងមក ព្រះ អង្គនឹងជាន់កំទេចវា ដោយរស្មីរុងរឿងរបស់ព្រះអង្គ»*។

ជាអកុសល គ្រូអធិប្បាយមួយចំនួន បានប្រើការបង្រៀនអំពីមេប្រឆាំងព្រះគ្រិស្តនេះដោយ បណ្តុះគំនិត

គ្រីស្ទានពីឥរិយាបថនៃការមិនឆ្លើយតប និងជំនឿជឿថា វាជាការដែលជៀសមិនរួចឡើយ។ «*មេប្រឆាំងនឹងព្រះគ្រិស្ត (អ្នកក្លែងខ្លួនធ្វើជាព្រះគ្រិស្ត) នឹងមកដល់*» ពួកគេបាននិយាយថា៖ «អ្វីៗកាន់តែអាក្រក់ទៅ អាក្រក់ទៅគ្មានអ្វី ធ្វើឲ្យប្រសើរឡើងឡើយ ហើយយើងមិនអាចធ្វើអ្វីបាន ទេ»។ ជាលទ្ធផលគ្រីស្ទានយ៉ាងច្រើន ជាញឹកញាប់បាន ពន្យាពេលនិងឱបដៃ ដោយមានការស្រងាកចិត្តជាខ្លាំង បានត្រឹមតែឈរមើល នូវការបំផ្លិចបំផ្លាញរបស់មារសាតាំង ដែលបណ្ដាលមកពី ពួកគេមិនបានទប់ស្កាត់ និង ពិនិត្យអ្វីទាំងអស់ដែលនៅជុំវិញខ្លួនគេឲ្យបានដិតដល់។

ឥរិយាបថនៃការមិនឆ្លើយតប និងជឿថាវាជាការដែលជៀសមិនរួច គឺដូចជាសោកនាដកម្មមួយ ដែលមិនមែនមកពីបទគម្ពីរទេ។ វាគឺជាការពិត ដែលថាមេប្រឆាំងព្រះគ្រិស្ត នៅទីបំផុតត្រូវតែលេចឡើង។ ប៉ុន្តែ វាឃ្លាតឆ្ងាយពីសេចក្ដីពិតពេក នៅពេលនេះដែលថាយើងមិនអាចធ្វើអ្វីបាន ដើម្បីទប់ស្កាត់ឥទ្ធិពលរបស់វាបាននោះ។

# ឥទ្ធិពលដែលកំពុងទប់ស្កាត់

មកទល់នឹងបច្ចុប្បន្ននេះ មានឥទ្ធិពលមួយ ដែលធ្វើការនៅលើពិភពលោក ដោយមានវិវាទតទល់ប្រឆាំង និងទប់ស្កាត់វិញ្ញាណរបស់មេប្រឆាំងព្រះគ្រិស្តនេះ។

អំណាចដែលកំពុងទប់ស្កាត់នេះ គឺជាវត្តមានផ្ទាល់របស់ព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងក្រុមជំនុំ ដែលបច្ចុប្បន្នបានការពារជាសម្ងាត់ពីការលេចចេញទាំងមូល និងចុងក្រោយរបស់មេប្រឆាំងព្រះគ្រិស្ត។នៅពេលយើងមើលតាមបទគម្ពីរ ការបើកសម្តែង បានលាតត្រដាងកាន់តែច្បាស់ អំពីបុគ្គល និងការងាររបស់ព្រះវិញ្ញាណបរិសុទ្ធ។

នៅទំព័រដំបូងរបស់ព្រះគម្ពីរ នៅក្នុង**លោកុប្បត្តិ១:២** យើងត្រូវបានប្រាប់ថា៖ *«ព្រះវិញ្ញាណ របស់ព្រះជាម្ចាស់ នៅរេរាពីលើផ្ទៃទឹក»។* ចាប់ពីពេលនោះមកនៅក្នុងគម្ពីរសញ្ញាចាស់ទាំងមូល មានសេចក្តីយោងជាញឹកញាប់អំពីសកម្មភាព របស់ព្រះវិញ្ញាណបរិសុទ្ធ នៅលើផែនដីនេះ។ ទោះជាបីជាយ៉ាងណាក៏ដោយ នៅចុងបញ្ចប់នៃព័ន្ធកិច្ចរបស់ទ្រង់ នៅលើផែនដី ព្រះយេស៊ូបានសន្យានឹងពួកសិស្សរបស់ទ្រង់ថា ព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកក្នុងរយៈពេលដ៏ខ្លីខាងមុខ មកកាន់ពួកគេតាមរបៀបថ្មីមួយខុសប្លែក ហើយដែលមិនធ្លាប់បានកើតឡើងនៅលើផែនដីពីមុនមក។

# ព្រះដ៏ជួយការពារតាមព្រះបន្ទូលសន្យា

នៅក្នុង**យ៉ូហាន ១៤:១៦-១៧** ព្រះយេស៊ូមានព្រះ បន្ទូលសន្យាថា៖«*ខ្ញុំនឹងទូលអង្វរព្រះបិតា ហើយទ្រង់ប្រទានព្រះដ៏ជួយការពារ (ព្រះដ៏ជួយកំសាន្តចិត្ត) មួយអង្គទៀត អោយគង់នៅជាមួយអ្នករាល់គ្នាជា ដរាបរៀងទៅ ព្រះអង្គជាព្រះវិញ្ញាណ ដែលសំដែងសេចក្តីពិត ...ព្រោះព្រះអង្គ ស្ថិតនៅជាប់នឹងអ្នករាល់គ្នា ហើយព្រះអង្គនឹងគង់ក្នុងអ្នករាល់គ្នា។* យើងអាចពន្យល់បានយ៉ាងទូលំទូលាយ នូវព្រះបន្ទូលសន្យារបស់ព្រះយេស៊ូដូចតទៅនេះ៖ « ខ្ញុំមានវត្តមានផ្ទាល់ នៅជាមួយនឹងអ្នក រាល់គ្នា អស់រយៈពេលបីឆ្នាំកន្លះហើយ ឥឡូវខ្ញុំត្រូវចាកចេញពីអ្នករាល់គ្នា។ បន្ទាប់ពីខ្ញុំចាកចេញទៅ នឹងមានបុគ្គលផ្សេងទៀតមកជំនួសកន្លែងរបស់ខ្ញុំ។ បុគ្គលនេះគឺជាព្រះវិញ្ញាណបរិសុទ្ធ។ នៅពេលទ្រង់យាងមក នោះទ្រង់នឹងគង់នៅជាមួយអ្នកជារៀងរហូត»។

ព័ន្ធកិច្ចដ៏អស្ចារ្យរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងក្រុមជំនុំ គឺត្រូវរៀបចំរូបកាយឲ្យបានពេញលេញសម្រាប់ព្រះគ្រិស្ត។ ពេលបញ្ចប់រួចរាល់ហើយ រូបកាយនេះ នឹងប្រែក្លាយទៅជាកូនក្រមុំ ដែលនាំទៅថ្វាយព្រះគ្រិស្ត ដូចជាកូនក្រមុំ ដែលនាំទៅអោយកូនកម្លោះអញ្ជឹងដែរ។ ព័ន្ធកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងក្រុមជំនុំ ចប់ពេលណា ពេលនោះព្រះអង្គ នឹងនាំយកព្រះកាយរបស់ព្រះ

គ្រិស្តចេញពីផែនដី ទៅជាមួយព្រះអង្គ។ ដូច្នេះ យើងអាចថ្លែងឡើងវិញ នូវការថ្លែងរបស់លោកប៉ូល ក្នុង **២ថែស្សាឡូនីច ២:៧** ដូចខាងក្រោម៖ «*ដ្បិតសេចក្ដីអាថ៌ កំបាំងរបស់ការទទឹងច្បាប់កំពុងតែបណ្ដាលឡើងហើយ ប៉ុន្តែមាន១អង្គ ដែលឃាត់ឃាំងវាសព្វថ្ងៃនេះ ទាល់តែបានដកទ្រង់ចេញទៅ*»។

នៅក្នុងពិភពលោក មានវិញ្ញាណនៃមេប្រឆាំងព្រះគ្រិស្ត ដែលបានធ្វើការឆ្ពោះទៅរក ការលេចឡើងនៃមេប្រឆាំងព្រះគ្រិស្តផ្ទាល់។ នៅក្នុងពួកសិស្សរបស់ព្រះគ្រិស្ត មានព្រះវិញ្ញាណបរិសុទ្ធ ដែលធ្វើការការពាររារាំងការលេចឡើងនៃមេប្រឆាំងព្រះគ្រិស្ត។ ហេតុនេះហើយបានជាពួកសិស្ស ដែលមានព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយ បានធ្វើជាឧបសគ្គមួយ ក្នុងការរារាំងយ៉ាងខ្លាំងក្លាបំផុតចំពោះការទទឹងច្បាប់និងការលេចឡើងចុងក្រោយរបស់មេប្រឆាំងព្រះគ្រិស្ត។ មានតែនៅពេល ដែលព្រះវិញ្ញាណបរិសុទ្ធ រួមជាមួយនឹងរូបកាយដ៏ពេញលេញនៃពួកសិស្សរបស់ព្រះគ្រីស្ទ ត្រូវបានដកចេញពីផែនដីប៉ុណ្ណោះ ទើបអំណាចនៃការទទឹងច្បាប់ នឹងអាចបន្តដោយគ្មានការរាំងស្ទះរហូតទៅចំណុចខ្ពស់បំផុត នៃគោលបំណងរបស់ពួកវាតាមមេប្រឆាំងព្រះគ្រិស្ត។ទន្ទឹមនឹងនេះដែរ វាគឺជាឯកសិទ្ធិ និងការទទួលខុសត្រូវនៃពួកសិស្សរបស់ព្រះគ្រិស្តតាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធធ្វើការដើម្បី «យកឈ្នះ» លើអំណាចរបស់មេប្រ

ឆាំងព្រះគ្រិស្ត និងបញ្ឈប់ការកើនឡើងនៃអំណាចរបស់ពួកវា។

# អំបិលដែលមានភាពជោគជ័យ

ក្នុងនាមជាអំបិលសម្រាប់មនុស្សលោក យើងដែលជាពួកសិស្សរបស់ព្រះគ្រិស្ត មានការទទួលខុសត្រូវចម្បងពីរ។ ទីមួយ តាមរយៈវត្តមានរបស់យើងនៅលើផែនដី ដែលសរសើរតម្កើងព្រះគុណ និងព្រះហឫទ័យមេត្តាករុណាមិនចេះអស់របស់ព្រះជាម្ចាស់។ ទីពីរ តាមរយៈឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលនៅក្នុងខ្លួនយើង យើងបញ្ឈប់ការកើនឡើងនូវអំណាចនៃសេចក្តីពុករលួយ និងការទទឹងច្បាប់ រហូតដល់ពេលវេលាកំណត់របស់ព្រះជាម្ចាស់បានមកដល់។

នៅក្នុងការបំពេញទំនួលខុសត្រូវទាំងនេះ ក្រុមជំនុំឈរជាឧបសគ្គ ចំពោះការសម្រេចបាននូវមហិច្ឆតាដ៏កំពូលរបស់អារក្សសាតាំង ដែលចង់ទទួលបាននូវអំណាចគ្រប់គ្រងលើផែនដីទាំងមូល។ នេះពន្យល់អំពីហេតុអ្វីបានជាលោកប៉ូលនិយាយនៅក្នុង ២ថេស្សាឡូនិច ២:៣ថា៖ «*កុំឲ្យអ្នកណាបញ្ឆោតអ្នករាល់ គ្នាជាយ៉ាងណាដែរ ដ្បិតថ្ងៃនោះមិនមកឡើយ ទាល់តែមានសេចក្តីក្បត់សាសនាមកជាមុន ហើយមនុស្សដែលជាតួបាបនោះបានលេចមក គឺជាមនុស្សដែលត្រូវហិនវិនាស* »។

ពាក្យថា «លះបង់ជំនឿ» ត្រូវបានបក ប្រែថា«ក្បត់សាសនា» នេះហើយគឺជាការចេញពី សេចក្តីជំនឿ។

ដរាបណា ក្រុមជំនុំឈរមាំ ហើយមិនសម្របសម្រួលជំនឿរបស់ខ្លួន នោះក្រុមជំនុំ នៅតែមានអំណាចក្នុងការទប់ស្កាត់ នូវការសម្តែងចេញចុងក្រោយរបស់មេប្រឆាំងព្រះគ្រិស្ត។ សាតាំងផ្ទាល់ វាយល់យ៉ាងច្បាស់ អំពីរឿងនេះ ហេតុដូច្នេះហើយ បានជាគោលបំណងចម្បងរបស់វា គឺត្រូវធ្វើឱ្យប៉ះពាល់ដល់សេចក្តីជំនឿ និងសេចក្តីសុចរិតរបស់ក្រុមជំនុំ។ នៅពេល ដែលវាសម្រេចការនេះបាន នោះឧបសគ្គចំពោះគោលបំណងរបស់វា ត្រូវបានយកចេញ ហើយទ្វារត្រូវបានបើកចំហរសម្រាប់វា ដើម្បីទទួលបាននូវអំណាចទាំងពីរ ទាំងខាងវិញ្ញាណនិងទាំងខាងនយោបាយនៅលើផែនដីទាំងមូល។

ឧបមាថា អារក្សសាតាំងទទួលបានជោគជ័យ ដោយសារយើង ជាពួកគ្រីស្ទានបរាជ័យ មិនបានបំពេញការទទួលខុសត្រូវរបស់យើង។ តើមានអ្វីកើតឡើងបន្ទាប់ពីហ្នឹង? ព្រះយេស៊ូផ្ទាល់ បានផ្តល់ឱ្យយើង នូវចម្លើយ។ យើងបានក្លាយទៅជា «អំបិល ដែលបានបាត់ជាតិប្រៃ»។ ទ្រង់បានព្រមានយើង ពីជោគវាសនា ដែលកំពុងរង់ចាំអំបិល ដែលបាត់ជាតិប្រៃបែបនេះថា៖ «អំបិលនោះគ្មានប្រយោជន៍អ្វីទៀតទេ គឺមានតែបោះចោលទៅខាងក្រៅអោយមនុស្សដើរជាន់ប៉ុណ្ណោះ» (ម៉ាថាយ ៥:១៣) ។

«គ្មានប្រយោជន៍អ្វីទៀតទេ» តាមពិត នោះគឺជាការ ថ្កោលមួយយ៉ាងធ្ងន់ធ្ងរ។ បន្ទាប់ពីហ្នឹង មានអ្វីកើតឡើងទៀត? យើងត្រូវបាន «បោះចោលទៅខាងក្រៅ» -ត្រូវបានព្រះជាម្ចាស់បដិសេធ។ បន្ទាប់មក យើងត្រូវបាន «អោយមនុស្សដើរជាន់» មនុស្សក្លាយជាឧបករណ៍របស់ព្រះជាម្ចាស់ក្នុងការវិនិច្ឆ័យទោស ទៅលើអំបិល ដែលបាត់ជាតិប្រៃ(ក្រុមជំនុំដែលក្បត់ជំនឿ)។ប្រសិនបើយើងនៅក្នុងក្រុមជំនុំ បរាជ័យក្នុងការទប់ស្កាត់អំណាច នៃសេចក្តីអាក្រក់ នោះខ្លួនយើង នឹងត្រូវបានប្រគល់ទៅឲ្យអំណាចទាំងនោះ ធ្វើការវិនិច្ឆ័យទោសយើងវិញ ជាមិនខានឡើយ។

លោកប៉ូល បានណែនាំយ៉ាងច្បាស់ នូវការឆ្លាស់គ្នាចំនួនពីរ ដល់យើងនៅក្នុងរ៉ូម១២:២១ថា៖ «មិនត្រូវចាញ់ការអាក្រក់ឡើយ គឺត្រូវឈ្នះការអាក្រក់ ដោយប្រព្រឹត្តអំពើល្អវិញ»។មានជម្រើសតែពីរប៉ុណ្ណោះសម្រាប់យើង៖ «ត្រូវយកឈ្នះ ឬត្រូវបានចាញ់» ។ គ្មានកន្លែងកណ្តាលក៏គ្មានជម្រើសទីបី សម្រាប់ឲ្យ យើងជ្រើសរើសដែរ។ យើងអាចប្រើសេចក្តីល្អ ដែលព្រះជាម្ចាស់បានដាក់នៅក្នុងយើង ដើម្បីយកឈ្នះការអាក្រក់ ដែលយើងប្រឈមមុខ។ ប៉ុន្តែប្រសិនបើ យើងបានបរាជ័យចំពោះវា នោះសេចក្តីអាក្រក់ នឹងយកឈ្នះលើយើងវិញមិនខាន។

សារនេះត្រូវអនុវត្តជាបន្ទាន់ ពិសេសចំពោះយើងទាំងអស់គ្នា ដែលរស់នៅក្នុងទឹកដី ជាកន្លែងដែល

យើង កំពុងរីករាយនឹងសេរីភាព ក្នុងការប្រកាស និង អនុវត្តសេចក្តីជំនឿជាគ្រីស្ទានរបស់យើង។ នៅតាមណ្តាប្រទេសមួយចំនួនបច្ចុប្បន្ននេះគ្រីស្ទាន ត្រូវបានបាត់បង់នូវ សេរីភាពបែបនេះ។ នៅពេលជាមួយគ្នានេះដែរ ក៏មានមនុស្សរាប់លាននាក់ នៅក្នុងប្រទេសទាំងនោះ ត្រូវបានគេបញ្ចុះបញ្ចូលជាប្រព័ន្ធឲ្យស្អប់និងមិនចូលចិត្តគ្រីស្ទាននិងចំពោះអ្វីៗទាំងអស់ ដែលតំណាងឲ្យជំនឿគ្រីស្ទាន ដែរ។ ដូច្នេះ មនុស្ស ដែលត្រូវបានគេបញ្ចុះបញ្ចូលនោះ មិនមានអ្វីធំដុំជាងការដែលគ្រីស្ទាន ដែលមិនទាន់ស្ថិតនៅក្រោមនឹមរបស់ពួកគេត្រូវបានជាន់ឈ្លី ដោយជើងរបស់ពួកគេនោះទេ។

ប្រសិនបើយើង ធ្វើតាមការព្រមានរបស់ព្រះយេស៊ូ និងបំពេញមុខងាររបស់យើងដូចជាអំបិលនៅលើផែនដី នោះយើងមានអំណាចដើម្បីទប់ស្កាត់ការនេះ។ ប្រសិនបើយើង ខកខានមិនបាន ធ្វើតាមមុខងាររបស់យើង ហើយរងទុក្ខនៅក្នុងការវិនិច្ឆ័យទោសមែននោះ ការឆ្លុះបញ្ចាំង ដែលល្វីងជូរចត់បំផុតនោះ នឹងជា៖ រឿងនេះ វាមិនគួរកើតឡើងសោះ។

ដកស្រង់ពីអត្ថបទស្រាទំពាំងបាយជូរថ្មី ខែមេសាឆ្នាំ ១៩៧៦

ប្រែសម្រួលជាភាសាខ្មែរដោយ

**អង្គការមួយសម្រាប់មួយកម្ពុជា**

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមក

ការិយាល័យយើងខ្ញុំតាមរយៈ

អាសយដ្ឋាន: ផ្ទះលេខ៣៨-៣៨អា ផ្លូវ ៣៣៦ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ទូរស័ព្ទលេខ: ០២៣ ៦៧ ៥៥៥ ៨៦

គេហទំព័រ: www.one2oneword.org

# អង្គការមួយសម្រាប់មួយកម្ពុជា

បានទទួលសិទ្ធិ

ក្នុងការប្រែសម្រួលទៅជាភាសាខ្មែរ

នៅក្នុងការិយាល័យព័ន្ធកិច្ចដេរេកព្រីនស៍

(Derek Prince)

ប្រចាំនៅប្រទេសកម្ពុជា តាមរយៈ

ព័ន្ធកិច្ចដេរេកព្រីនស៍ប្រចាំនៅតំបន់អាស៊ី-ប៉ាស៊ីភិច


ទំនាក់ទំនងអាសយដ្ឋាន ផ្លូវហដុន៣៨

ប្រអប់សំបុត្រ ២០២៩

ព្រះវិហារព្រះគ្រិស្ត ៨១៤០

ប្រទេសណូវ៉ែសឺឡង់

ទូរស័ព្ទលេខ : ០០៦៤ ៣ ៣៦៦ ៤៤៤៣

ទូរសារ : ០០៦៤  ៣ ៣៦៦ ១៥៦៩

អ៊ីម៉ែល admin@dpm.co.nz

គេហទំព័រ www.dpm.co.nz